**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Nov-2012, 14:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ទាក់ទងនឹងការកំណត់កាលបរិច្ឆេទ និងទំព័រកំណត់ សម្រាប់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

ជនជាប់ចោទ
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ
លោក សុន អរុណ
លោក Michiel PESTMAN

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ពេជ អង្គ

Elisabeth SIMONNEAU FORT

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក គង់ សំអុន

Anta GUISSÉ

លោក Arthur VERCKEN

លោក Jacques VERGÈS

# I. សេចក្តីផ្តើម

១- កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់ “សំណើសុំពិនិត្យសាជាថ្មីតាមសេចក្តីបង្គាប់នៃអនុស្សរណៈលេខE163/5 ដែលតម្រូវឱ្យភាគីធ្វើការដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនស្តីពីច្បាប់ដែលត្រូវអនុវត្ត ឱ្យបានមុនថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២”[1] (“សំណើរបស់ ខៀវ សំផន”) ដែលនៅក្នុងនោះ ខ្លួនបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិចារណាទៅលើកថាខណ្ឌទី៤ នៃអនុស្សរណៈដែលមានចំណងជើងថា “សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់ដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលអំពីផ្នែកច្បាប់ជាធរមាន” (“អនុស្សរណៈ”)[2]។

២- នៅក្នុងអនុស្សរណៈនោះ អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យភាគីដាក់ “ផ្នែកនានានៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឱ្យបានមុនពេលនៃការបញ្ចប់ការពិភាក្សាដេញដោលភ័ស្តុតាងលើសំណុំរឿង០០២/០១” និងបានបង្គាប់ឱ្យភាគី កម្រិតសេចក្តីសន្និដ្ឋានទាំងនោះមិនឱ្យលើសពី២០ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ឬ៤០ទំព័រ ជាភាសាខ្មែរ។ អង្គជំនុំជម្រះសាលាដំបូង បានកំណត់កាលបរិច្ឆេទសម្រាប់ដាក់ផ្នែកទាំងនេះនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលត្រឹមថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ប៉ុន្តែបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងធ្វើការពិចារណាលើការស្នើសុំពន្យារពេលចំពោះឱសានវាទនេះ[3]។

៣- សំណើរបស់ ខៀវ សំផន បានសុំឱ្យអង្គជំនុំជម្រះពន្យារកាលបរិច្ឆេទកំណត់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ រហូតដល់ក្រោយការបញ្ចប់សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿងនេះ។ សំណើនេះ ក៏បានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការពន្យារពេលផងដែរ ចំពោះការសម្រេចណាមួយស្តីពីចំនួនទំព័រ ឬពេលវេលា

---

[1] ឯកសារលេខ **E163/5/2** “សំណើសុំពិនិត្យសាជាថ្មីតាមសេចក្តីបង្គាប់របស់អនុស្សរណៈលេខ E163/5 ដែលតម្រូវឱ្យភាគីធ្វើការដាក់សារណាជាលាយលក្ខណ៍អក្សរស្តីពីច្បាប់ធរមាន ឱ្យបានមុនថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២”, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ (“សំណើរបស់ ខៀវ សំផន”)។

[2] ឯកសារលេខ **E163/5** សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់ដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន”, ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ (“អនុស្សរណៈ”)។

[3] **E163/5** អនុស្សរណៈ, ត្រង់កថាខណ្ឌទី៤។

សម្រាប់ដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល រហូតទាល់តែមានភាពច្បាស់លាស់ស្តីពីវិសាលភាពដូចគ្នានោះ និងភស្តុតាងដែលបានជំនុំជម្រះនៅពេលសវនាការ[4]។

## II. ចម្លើយតប

### ក. ការកំណត់ពេលវេលា និងបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

៤- ខណៈដែលសហព្រះរាជអាជ្ញាបានសរសើរដល់សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង សំដៅសម្រួលដល់ការបញ្ចប់សវនាការឲ្យបានឆាប់រហ័ស សហព្រះរាជអាជ្ញាឯកភាពជាមួយនឹងមេធាវីការពារក្តីថា ការអនុញ្ញាតឲ្យភាគីដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលទាំងមូល (រួមទាំងសេចក្តីសន្និដ្ឋាននានាអំពីច្បាប់ជាធរមាន) បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធីលើភស្តុតាង អាចជួយសម្រួលដល់ការវិភាគមួយដែលរឹតតែមានប្រយោជន៍ និងរឹតតែមានប្រសិទ្ធភាពថែមទៀតដែលភាគីបានគិតគូរអំពី បញ្ហាអង្គច្បាប់ អង្គហេតុ និងភស្តុតាងទាំងអស់ដែលត្រូវបានដោះស្រាយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់នេះ។ វាទំនងជានឹងមានការពិបាកខ្លាំងនៅក្នុងការលើកឡើងអំពីច្បាប់ជាធរមាននៅមុនពេលការវាយតម្លៃបញ្ចប់លើភស្តុតាង និងការកំណត់បទចោទនៃបទល្មើសនានាដែលបានចោទប្រកាន់ជនជាប់ចោទ។

៥- សហព្រះរាជអាជ្ញាក៏ជូនសេចក្តីសន្និដ្ឋានផងដែរថា នៅក្នុងកាលៈទេសៈណាក៏ដោយ ការកំណត់ចំនួនទំព័រជារួម គួរត្រូវបានផ្តល់ជូនភាគីនីមួយៗ ក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដែលអាចធ្វើឲ្យភាគីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការប្រើប្រាស់នូវការផ្តល់ជូនទៅតាមរបៀបមួយមានប្រសិទ្ធភាព និងមានលក្ខណៈសន្សំសំចៃ។ ការដាក់សេចក្តីសន្និដ្ឋានលើអង្គច្បាប់ និងអង្គហេតុដាច់ដោយឡែកពីគ្នា នឹងនាំឲ្យមានការត្រួតគ្នា ក្នុងកម្រិតណាមួយចៀសមិនផុតឡើយ។ បន្ថែមលើនេះ ការកម្រិតត្រឹមតែចំនួន២០ទំព័រ សម្រាប់ធ្វើសេចក្តីសន្និដ្ឋានផ្នែកច្បាប់ជាធរមាន អាចបង្ហាញថាមិនគ្រប់គ្រាន់ទេ សម្រាប់សហព្រះរាជអាជ្ញាដោះស្រាយគ្រប់បទល្មើសទាំងអស់, ទម្រង់នៃការទទួលខុសត្រូវ, គោលការណ៍ផ្តន្ទាទោស និងវិធានផ្សេងៗដែលគ្រប់គ្រងលើការវាយតម្លៃទៅលើភស្តុតាងនៅក្នុងសំណុំរឿងនេះ។ ការធ្វើសេចក្តីសន្និដ្ឋានធំមួយនោះ អាចលទ្ធភាពស្រួបបាននូវការវិភាគបញ្ហាកាន់តែមានប្រសិទ្ធភាព ចៀសវាងបាននូវការត្រួតគ្នា និងប្រើប្រាស់បាននូវការផ្តល់ជូនចំនួនទំព័រទាំងអស់របស់សហព្រះរាជអាជ្ញា ទៅតាមរបៀបមួយកាន់តែមានប្រសិទ្ធភាព។

[4] ឯកសារលេខ **E163/5/2** សំណើរបស់ ខៀវ សំផន, កថាខណ្ឌទី២៤។

## ២. ចំនួនទំព័រកំណត់ជារួម

៦- សហព្រះរាជអាជ្ញារំឭកឡើងវិញថា បញ្ហានៃការកំណត់ចំនួនទំព័រជារួម សម្រាប់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ឥឡូវនេះ កំពុងតែស្ថិតនៅក្នុងការពិចារណារបស់អង្គជំនុំជម្រះ។ ដើម្បីជាប្រយោជន៍ក្នុងការជួយបង្កលក្ខណៈងាយស្រួលដល់ការបញ្ចប់សវនាការនេះឲ្យបានឆាប់រហ័ស សហព្រះរាជអាជ្ញាបានកាត់បន្ថយយ៉ាងច្រើនចំនួនទំព័រដែលត្រូវការ សម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន។ នៅក្នុងការដាក់ឯកសារជាលាយលក្ខណ៍អក្សរទាំងពីររបស់ខ្លួន នៅមុនកិច្ចប្រជុំរៀបចំសវនាការ និងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានស្នើចំនួន១៨០ទំព័រ (ជាភាសាអង់គ្លេស) សម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងចំនួន៦០ទំព័រសម្រាប់ជនជាប់ចោទម្នាក់ៗ[5]។ សហព្រះរាជអាជ្ញារំឭកថា កាលពីនៅក្នុងសំណុំរឿងលេខ០០១ ករណីមួយជាប់ទាក់ទងនឹងជនជាប់ចោទម្នាក់ដែលមានអង្គហេតុច្រើនបានចោទប្រកាន់ប្រឆាំងនឹងរូបគាត់ សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញរបស់សហព្រះរាជអាជ្ញា កាលនោះ មានចំនួន១៥៨ទំព័រ ជាភាសាអង់គ្លេស និងចំនួន២៥០ទំព័រ ជាភាសាខ្មែរ[6]។ ក្នុងករណីនេះ ចំនួនទំព័រដែលបានស្នើសុំ បង្ហាញពីការសម្របសម្រួលច្រើនរបស់សហព្រះរាជអាជ្ញា ដើម្បីស្របទៅតាមបំណងច្បាស់លាស់របស់អង្គជំនុំជម្រះ ដើម្បីឲ្យសេចក្ដីសន្និដ្ឋានបញ្ចប់នេះបានខ្លី និងច្បាស់។

៧- សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា អនុស្សរណៈបែងចែកចំនួនទំព័រដូចៗគ្នា អោយភាគីនីមួយៗក្នុងការដាក់សារណារបស់ខ្លួនតាមវិធានច្បាប់ជាធរមាន។ សហព្រះរាជអាជ្ញាបារម្ភថាវិធីសាស្ត្រនេះអាចនាំឲ្យមានការបែងចែកមួយដែលមិនមានសមាមាត្រនូវការកំណត់ចំនួនទំព័ររួមទាំងអស់ និងដែលនាំឲ្យសិទ្ធិអំណាចមិនស្មើភាពគ្នារវាងភាគីនានានៅចំពោះមុខតុលាការ។ សហព្រះរាជអាជ្ញាទទួលខុសត្រូវក្នុងការបង្ហាញភ័ស្តុតាងអំពីពិរុទ្ធភាពរបស់ជនជាប់ចោទម្នាក់ៗ ក្នុងចំណោមជនជាប់ចោទទាំងអស់អោយមានភាពច្បាស់លាស់ ហួសពីវិមតិសង្ស័យទាក់ទងនឹងការចោទប្រកាន់ទាំងឡាយដែលពួកគេកំពុងប្រឈម។ សូម្បីតែនៅក្នុងបរិបទនៃការដាក់សារណាផ្នែកច្បាប់នានា ចាំបាច់តម្រូវឲ្យមាន

[5] ឯកសារលេខ **E1/114.2** ប្រតិចារឹក, កិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ត្រង់លេខ ERN 00843675 និង ឯកសារលេខ **E218/2** សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាសការ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២, ត្រង់កថាខណ្ឌទី៣២។

[6] សំណុំរឿងលេខ០០១, ឯកសារលេខ **E159/9** ដីកាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩។

ការពិនិត្យទូលំទូលាយលើគោលការណ៍នានានៃច្បាប់សារធាតុ ជាងអ្វីដែលតម្រូវដោយក្រុមមេធាវីការពារក្តីនីមួយៗ។ ហេតុនេះ ការអនុញ្ញាតឲ្យមេធាវីការពារក្តីនីមួយៗ មានចំនួនទំព័រដូចៗគ្នាចំពោះការដាក់សារណារបស់ខ្លួន ដូចចំនួនទំព័រសរុបដែលចែកទៅឲ្យសហព្រះរាជអាជ្ញានោះ បានធ្វើឲ្យសហព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពបាត់បង់អត្ថប្រយោជន៍ដែលជាការមិនត្រឹមត្រូវ។ ការមិនស្មើភាពគ្នានេះ មុខជានឹងធ្វើឲ្យឃើញច្បាស់ជាងនេះថែមទៀត ប្រសិនជាចំនួននេះត្រូវបានយកមកប្រើជាមួយនឹងចំនួនទំព័រកំណត់ជារួម សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ សហព្រះរាជអាជ្ញាចាំបាច់ត្រូវការពិនិត្យ និងធ្វើសេចក្តីសន្និដ្ឋានដែលមានបរិមាណនៃឯកសារភ័ស្តុតាង និងអង្គហេតុធំជាងមេធាវីការពារក្តីនិមួយៗឆ្ងាយណាស់។

៨- ដូចដែលសហព្រះរាជអាជ្ញាបានជូនជាមតិ ដើម្បីពិចារណាកាលពីមុនមកហើយថា អង្គជំនុំជម្រះគួរតែកំណត់ចំនួនទំព័រនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលឲ្យបានសមាមាត្រគ្នា ដើម្បីឲ្យដូចការអនុវត្តរបស់ខ្លួន នៅពេលធ្វើការបែងចែកពេលវេលាសម្រាប់សួរដេញដោលសាក្សីដែរ។ សហព្រះរាជអាជ្ញាបានដាក់បញ្ចូល ដោយយោងទៅលើការដាក់សេចក្តីសន្និដ្ឋានកាលពីមុនៗរបស់ខ្លួនលើបញ្ហានេះ អំពីចំនួនទំព័រកំណត់ជារួម អំពីការបែងចែកដោយសមាមាត្រនូវចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[7]។

៩- សហព្រះរាជអាជ្ញាកត់សំគាល់ថា ក្នុងសំណើរបស់ ខៀវ សំផន បានយល់ព្រមថា សហព្រះរាជអាជ្ញាត្រូវការចំនួនទំព័រច្រើនជាងខាងមេធាវីការពារក្តី ដោយសារថា សហព្រះរាជអាជ្ញាត្រូវដោះស្រាយការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទដែលមានច្រើននាក់[8]។ មេធាវីការពារក្តីអន្តរជាតិរបស់ អៀង សារី គឺលោក Michael Karnavas ក៏បានទទួលស្គាល់ផងដែរ អំពីបន្ទុកខុសគ្នារវាងអយ្យការ និងមេធាវីការពារក្តី ដោយបាននិយាយថា នៅក្នុងកិច្ចប្រជុំដឹកនាំសវនាការ៖ “ខ្ញុំគិតថា-១៨០ទំព័រសម្រាប់ឲ្យខាងអយ្យការ គឺជាការគ្រប់គ្រាន់ ក៏ប៉ុន្តែខ្ញុំមិនគិតថា ដោយសារសហព្រះរាជអាជ្ញាទទួលបាន១៨០ទំព័រ ហើយពួកយើងគួរតែទទួលបាន៦០ទំព័រនោះទេ។ ពួកយើងជឿថា ១០០ ទៅ១២០ទំព័រទើបគ្រប់គ្រាន់”[9]។

---

[7] ឯកសារលេខ **E218/2** សេចក្តីជូនដំណឹងអំពីគោលជំហររបស់សហព្រះរាជអាជ្ញា លើបញ្ហាគន្លឹះនានាដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហាឆ្នាំ២០១២, ចុះថ្ងៃទី១៥ សីហា ២០១២, កថាខណ្ឌទី២៩-៣៩។

[8] ឯកសារលេខ **E163/5/2** សំណើរបស់ ខៀវ សំផន, កថាខណ្ឌទី២០។

[9] ឯកសារលេខ**E1/114.2** ប្រតិចារឹក, កិច្ចប្រជុំរៀបចំសវនាការ, ចុះថ្ងៃទី២៧ សីហា ២០១២, ជាភាសាអង់គ្លេស លេខ ERN 00843681។

*សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/អជសង*

## III. សេចក្តីសន្និដ្ឋាន

១០- ជាសេចក្តីសន្និដ្ឋាន សហព្រះរាជអាជ្ញា៖

ក. យល់ព្រមថា កាលបរិច្ឆេទកំណត់តែមួយ គួរបានកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (រួមទាំងការដាក់សារណាទាក់ទងនឹងអង្គច្បាប់) ដែលអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់ សម្រាប់ភាគីនីមួយៗ ដើម្បីពិនិត្យមើលលើបញ្ហាទាំងអស់ពាក់ព័ន្ធនឹងអង្គច្បាប់ និងអង្គហេតុ បន្ទាប់ពីបញ្ចប់ដំណើការនីតិវិធីលើភ័ស្តុតាង។

ខ. សូមស្នើដោយគោរពដល់អង្គជំនុំជម្រះ ដើម្បីធានាឲ្យបានប្រាកដថា គោលការណ៍ស្តីពីសមាមាត្រ និងស្តីពីសិទ្ធិស្មើភាពគ្នា នៅចំពោះមុខតុលាការ ក៏ដូចជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការបង្ហាញភ័ស្តុតាងដាក់បន្ទុកទាក់ទងទៅនឹងជនជាប់ចោទទាំងបីត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការបែងចែកចំនួនទំព័រ សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និង

គ. យល់ព្រមថា កាលបរិច្ឆេទកំណត់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ គួរបានពន្យារពេលសិនរហូតដល់ថ្ងៃបញ្ចប់ការជំនុំជម្រះក្តី ឬយ៉ាងហោចណាស់ រហូតដល់មានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហានេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |